នីតិជាតិសាធារណៈ



សមាគមសាលាត្រាជូ

SALA TRAJU ASSOCIATION

ឯកិមុខចារសាធារណៈ

ស្តីពី

ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល

នៅប្រទេសកម្ពុជា

ខែ ធ្នូ ឆ្នាំ ២០១៨

ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ

ដោយៈ ម៉ៅ សិលា

Shared by Eang Samang

ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជ្ញ

ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលនៅប្រទេសកម្ពុជា

ដោយលោក **ម៉ៅ សិលា***

អត្ថន័យសង្ខេប

ក្នុងផ្នែកនីតិសាស្ត្រ ការសិក្សាលើប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការស៊ីវិលគឺជា ការសិក្សាទៅលើនីតិមួយប្រភេទដែលជាមែកធាងនៃនីតិសាធារណៈ ហៅថា "**នីតិមុខងារសាធារណៈ**"។ នីតិនេះសំដៅលើ បណ្តុំវិធានគតិយុត្តអនុវត្តចំពោះបុគ្គលិកគ្រប់ប្រភេទបំពេញការងារឱ្យរាជការ[1] ដែលក្នុងបរិបទកម្ពុជា ត្រូវបានគេស្គាល់ថាជាមន្ត្រីរាជការសាធារណៈ។ "**មន្ត្រីរាជការសាធារណៈ**" សំដៅទៅដល់មន្ត្រីទាំងអស់ធ្វើការក្នុងស្ថាប័នសាធារណៈ រាប់បញ្ចូលទាំងស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័នតុលាការ មានដូចជា មន្ត្រីរាជការស៊ីវិល នគរបាលជាតិ យោធិន មន្ត្រីតុលាការ ក្របខណ្ឌមន្ត្រីក្នុងស្ថាប័ននីតិប្បញ្ញត្តិ ឬក្របខណ្ឌមន្ត្រីដទៃទៀតដែលមានលក្ខន្តិកៈដោយឡែកពិសេស និងត្រូវបានតែងតាំងដោយលិខិតបទដ្ឋានគតិយុត្តដើម្បីបំពេញការងារក្នុងមុខងារសាធារណៈ[2]។ គិតត្រឹមខែមីនាឆ្នាំ២០១៦ សម្រាប់មន្ត្រីរាជការក្នុងក្របខណ្ឌស៊ីវិលនៅព្រះរាជាណាចក្រកម្ពុជា មានចំនួនសរុប ១៩០.០៩៨នាក់[3] ដែលធ្វើឱ្យការគ្រប់គ្រងមិនមែនជារឿងងាយស្រួលនោះទេ។

អត្ថបទនេះ នឹងសិក្សាដោយសង្ខេបលើប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ដោយផ្អែកទៅលើរាល់លិខិតបទដ្ឋានគតិយុត្ត និងស្ថាប័នទទួលបន្ទុកគ្រប់គ្រងមន្ត្រីរាជការនាពេលបច្ចុប្បន្ន ក្នុងនោះមានដូចជា លក្ខខណ្ឌក្នុងការចូលធ្វើការ សិទ្ធិនិងកាតព្វកិច្ចមន្ត្រីរាជការ របបប្រាក់កម្រៃជីវភាព ប្រាក់សោធននិវត្តន៍ រួមទាំងវិន័យនិងទណ្ឌកម្មទៅលើមន្ត្រីរាជការនាពេលមានកំហុស និងការដោះស្រាយទំនាស់ពាក់ព័ន្ធនឹងមុខងារសាធារណៈ។

គួរបញ្ជាក់ផងដែរថា ការសិក្សានេះនឹងផ្តោតតែទៅលើមន្ត្រីរាជការស៊ីវិលតែប៉ុណ្ណោះ ដោយមិនរាប់បញ្ចូលក្របខណ្ឌមន្ត្រីនគរបាលជាតិ យោធិន បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងបុគ្គលិកជាប់កិច្ចសន្យានិងអណ្តែតនោះទេ។

---

*បច្ចុប្បន្នជាមន្ត្រីរាជការក្រសួងយុត្តិធម៌ ព្រមទាំងជាសមាជិកគណៈកម្មការប្រតិបត្តិអាណត្តិទី២ និងជាអ្នកស្រាវជ្រាវជំបូងនៃសមាគមសាលាត្រាជ្ញ។ របៀបយោងឯកសារនេះ ÷ ម៉ៅ សិលា, " ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលនៅប្រទេសកម្ពុជា" , *ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជ្ញ*, ខែធ្នូ ឆ្នាំ២០១៨, < http://salatraju.com/post/443> , ថ្ងៃខែឆ្នាំចូលទស្សនា។

[1] បណ្ឌិត ស៊ិន សុឃន, នីតិមុខងារសាធារណៈ, បោះផ្សាយឆ្នាំ២០១៧, ទំព័រទី៤

[2] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣០(១)

[3] ចំនួននេះមិនរាប់បញ្ចូលមន្ត្រីនគរបាល មន្ត្រីយោធា អនុរក្សពន្ធនាគារ មន្ត្រីរាជការដែលទំនេរគ្មានបៀវត្ស ឬស្ថិតក្នុងស្ថានភាពផ្អើរមិនទាន់ទទួលបៀវត្សទេ។ សូមមើល ក្រសួងមុខងារសាធារណៈ, របាយការណ៍វឌ្ឍនភាពការងាររយៈពេល២ឆ្នាំកន្លះ (កញ្ញា២០១៣-មីនា២០១៦) និងទិសដៅការងារឆ្នាំ២០១៦, ខែមេសា ឆ្នាំ២០១៦, ទំព័រទី៨

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជ្ញ
ខែធ្នូ ឆ្នាំ២០១៨

មាតិកា

ក. ក្របខណ្ឌ ឋានន្តរសក្តិ ថ្នាក់ សន្ទស្សន៍បៀវត្ស លក្ខន្តិក:ដោយឡែកនៃអង្គផ្សេងៗ---------- ១

ខ. លក្ខខណ្ឌក្នុងការចូលក្របខណ្ឌ ---------- ៥

គ. កម្រៃជីវភាពប្រចាំខែរបស់មន្ត្រីរាជការ ---------- ៧

ឃ. របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវ: ---------- ៩

ង. សិទ្ធិ និងកាតព្វកិច្ចរបស់មន្ត្រីរាជការ---------- ១០

ច. វិន័យ ទណ្ឌកម្ម និងការចោទប្រកាន់តាមផ្លូវតុលាការ---------- ១១

ឆ. ការដោះស្រាយទំនាស់មុខងារសាធារណៈ:---------- ១២

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាក្រាដ
ខែធ្នូ ឆ្នាំ២០១៨

ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការស៊ីវិលនៅកម្ពុជាជា **ប្រព័ន្ធអាជីព** មានន័យថា បើក្លាយទៅជាមន្ត្រីរាជការក្នុងក្របខណ្ឌសាធារណៈគឺ អាចបំពេញការងាររហូតដល់ថ្ងៃចូលនិវត្តន៍ រៀរលែងតែបុគ្គលនោះបាត់បង់សម្បទាវិជ្ជាជីវៈ ឬទទួលទណ្ឌកម្មវិន័យ ដែលតម្រូវឱ្យបណ្តេញចេញពីក្របខណ្ឌ ឬទទួលមរណភាពក្នុងពេលបំពេញមុខងារ។

ក្នុងឆ្នាំ១៩៩៤ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំ **ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា** ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤។ ច្បាប់នេះ ត្រូវបានធ្វើវិសោធនកម្ម ២លើក គឺ ការធ្វើវិសោធនកម្មមាត្រា៥១ ក្នុងឆ្នាំ១៩៩៩ និងមាត្រា៩ មាត្រា១០ ក្នុងឆ្នាំ២០១៣។ ច្បាប់នេះគ្រប់គ្រងមន្ត្រីរាជការគ្រប់ប្រភេទ លើកលែងតែក្រុមមន្ត្រីក្នុងអង្គតុលាការ និងក្រុមមន្ត្រីក្នុងអង្គនីតិប្បញ្ញត្តិ[4]។ គោលការណ៍ធំៗដែលមានចែងក្នុងច្បាប់នេះ មានដូចជា÷

ក. ក្របខណ្ឌ ឋានន្តរសក្តិ ថ្នាក់ សន្ទស្សន៍បៀវត្ស លក្ខន្តិកៈដោយឡែកនៃអង្គផ្សេងៗ

គោលការណ៍រួមនៃមុខងារសាធារណៈត្រូវបានកំណត់ជាលើកដំបូងតាម **ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧** ដោយបែងចែកក្របខណ្ឌមន្ត្រីរាជការជា ៤ ក្របខណ្ឌគឺ **ក ខ គ** និង **ឃ**។ តាមរយៈកំណែទម្រង់ឆ្នាំ២០១៣ ព្រះរាជក្រឹត្យឆ្នាំ១៩៩៧ ត្រូវបាននិរាករណ៍ និងជំនួសដោយ **ព្រះរាជក្រឹត្យ លេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤** ដោយលុបក្របខណ្ឌ **ឃ**[5] និងបង្រួញថ្នាក់នៃមន្ត្រីរាជការឱ្យនៅតិចជាងមុន[6]។ ព្រះរាជក្រឹត្យនេះ បានកំណត់និយមន័យនៃ អង្គនៃមន្ត្រីរាជការស៊ីវិល ក្របខណ្ឌ ឋានន្តរសក្តិ និងថ្នាក់របស់មន្ត្រីរាជការ បានលម្អិត ដូចខាងក្រោម÷

- ***អង្គនៃមន្ត្រីរាជការស៊ីវិល*** ÷ ជាបណ្តុំនៃមន្ត្រីរាជការស៊ីវិលដែលទទួលបានការបណ្តុះបណ្តាលមានបទពិសោធន៍ការងារ និងចំណេះដឹង ព្រមទាំងបំពេញការងារក្នុងវិស័យតែមួយ ហើយអង្គនីមួយៗត្រូវបានបែងចែកជាក្របខណ្ឌ[7]។ អង្គនីមួយៗ ត្រូវបានរៀបចំ និងកំណត់ដោយព្រះរាជក្រឹត្យដោយឡែក។
- ***ក្របខណ្ឌ*** ÷ ជាបណ្តុំនៃមន្ត្រីរាជការស៊ីវិល ដែលមានគុណសម្បត្តិ ឬ ការបណ្តុះបណ្តាលដូចគ្នា ឬ ប្រហាក់ប្រហែលគ្នា ហើយមានឧបនិស្ស័យកាន់មុខតំណែង ឬ បំពេញមុខងារដូចគ្នាក្នុងអង្គតែមួយ[8]។ សព្វថ្ងៃ មាន ៣ក្របខណ្ឌ គឺ÷

  ក÷ អាចមានមុខងារក្នុងតំណែងដឹកនាំ គ្រប់គ្រង អធិការកិច្ច សវនកម្ម បណ្តុះបណ្តាល សិក្សាស្រាវជ្រាវ ផ្តល់យោបល់ គោលនយោបាយ ផែនការ និងទទួលខុសត្រូវអាស្រ័យតាមអង្គ។ កម្រិតអប្បបរមានៃការបណ្តុះបណ្តាលដែលអាចបញ្ចូលក្នុងក្របខណ្ឌនេះបានគឺ **បរិញ្ញាបត្រ ឬ សញ្ញាបត្រសមមូល**។ លក្ខន្តិកៈដោយឡែកក្នុងអង្គអាចកំណត់បន្ថែមបាន ប្រសិនចាំបាច់។

[4] ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលឆ្នាំ១៩៩៤, មាត្រា១ ។ ក្រុមមន្ត្រីទាំង ០២នេះ មានច្បាប់ដោយឡែកក្នុងការគ្រប់គ្រងរៀងៗខ្លួន។
[5] ព្រះរាជក្រឹត្យគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ, លេខ នស/រកត/១០១៤/១១៧៥, ០២ តុលា ២០១៤, មាត្រា៤
[6] ដដែល, មាត្រា១៦ និង១៧
[7] ដដែល, មាត្រា៤ កថាខណ្ឌ១
[8] ដដែល, មាត្រា៩

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាគ្រាជ្ញ
ខែទិច្ឆិកា ឆ្នាំ២០១៨

ក្របខណ្ឌ ក មាន ៣ ឋានន្តរសក្តិ។

ខ÷ អាចមានមុខងារក្នុងការរៀបចំការងារសម្រាប់អ្នកទទួលខុសត្រូវសម្រេច និងដាក់ឱ្យអនុវត្តការងារបណ្តុះបណ្តាល ធានាប្រតិបត្តិការនៃការងារ និងជួយគាំទ្រដល់ការងារមន្ត្រីរាជការក្នុងក្របខណ្ឌ ក អាស្រ័យតាមអង្គ។ កម្រិតអប្បបរមានៃការបណ្តុះបណ្តាលដែលអាចបញ្ចូលក្នុងក្របខណ្ឌនេះបានគឺ **សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបូក២ឆ្នាំ នៃការសិក្សាដោយមានសញ្ញាបត្រ**។ លក្ខន្តិក:ដោយឡែកក្នុងអង្គអាចកំណត់បន្ថែមបាន ប៉ុន្តែមិនត្រូវស្មើនឹងចំនួនឆ្នាំនៃក្របខណ្ឌ ក។ ក្របខណ្ឌ ខ មាន ៣ ឋានន្តរសក្តិ។

គ÷ អាចមានមុខងារក្នុងការងាររៀបចំការិយាល័យ លេខាធិការដ្ឋាន ការងារបណ្តុះបណ្តាលកម្រិតបឋម និងប្រតិបត្តិការធម្មតា ដែលតម្រូវឱ្យមានចំណេះបច្ចេកទេស ឬចំណេះធ្វើការងារជាក់លាក់ ដែលជាតម្រូវការនៃអង្គ។ កម្រិតអប្បបរមានៃការបណ្តុះបណ្តាលអាចកំណត់ដោយលក្ខន្តិក:ដោយឡែកនៃអង្គប៉ុ ន្តែមិនត្រូវឱ្យដូចលក្ខខណ្ឌកំណត់ក្នុងក្របខណ្ឌ ខ នោះឡើយ។ ក្របខណ្ឌ គ ពុំមានចែកជាឋានន្តរសក្តិនោះទេ។

- ***ឋានន្តរសក្តិ*** ÷ ជាលំដាប់ឋានានុក្រមនៃក្របខណ្ឌនីមួយៗ ហើយឋានន្តរសក្តិនីមួយៗឆ្លើយតបទៅនឹងមុខតំណែង ឬសារព័ន្ធមុខងារដែលមានការទទួលខុសត្រូវកាន់តែខ្ពស់។ នៅក្នុងឋានន្តរសក្តិ មានបែងចែកជា **ថ្នាក់** ។

ផ្អែកតាមនិយមន័យ និងការរៀបចំដូចខាងលើ មកទល់បច្ចុប្បន្ននេះ ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលនៅកម្ពុជាត្រូវបានបែងចែកជាអង្គ ក្របខណ្ឌ ឋានន្តរសក្តិ និងថ្នាក់ ដូចខាងក្រោមនេះ ÷

អង្គ	**ក្របខណ្ឌ**	**ឋានន្តរសក្តិ**	**ថ្នាក់**
អង្គរដ្ឋបាលទូទៅ[9]	ក	១. ឧត្តមមន្ត្រី	៦
		២. វរមន្ត្រី	៤
		៣. អនុមន្ត្រី	៤
	ខ	១. នាយក្រមការ	៦
		២. ក្រមការដើមខ្សែ	៤
		៣. ក្រមការ	៤
	គ	លេខាធិការរដ្ឋបាល	១០
	ក	១. ឧត្តមមន្ត្រី	៦

[9] ស្ថិតក្រោមការគ្រប់គ្រង របស់ក្រសួងមុខងារសាធារណៈ សម្រាប់បម្រើការងារនៅគ្រប់ក្រសួងស្ថាប័ន។ *សូមមើល* ព្រះរាជក្រឹត្យលេខ ជស/រកត/ ០៣០០/១១៦, ០៣ មីនា ២០០០ (ក្របខណ្ឌ ក), ព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦, ០៤ មេសា ២០០០ (ក្របខណ្ឌ ខ) និងព្រះរាជក្រឹត្យលេខ នស/រកត/ ០៥០០/១០៣, ៣១ ឧសភា ២០០០ (ក្របខណ្ឌ គ)

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជ្ញ
ខែទិច្ឆិកា ឆ្នាំ២០១៨

អង្គរដ្ឋបាលស៊ីវិលក្រសួងមហាផ្ទៃ[10]		២. វរមន្ត្រី	៤
		៣. អនុមន្ត្រី	៤
	ខ	១. នាយក្រមការ	៦
		២. ក្រមការដើមខ្សែ	៤
		៣. ក្រមការ	៤
	គ	លេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ	១០
អង្គបច្ចេកទេស[11]	ក	១. មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស	៦
		២. មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ	៤
		៣. មន្ត្រីបច្ចេកទេសជាន់ខ្ពស់	៤
	ខ	១. មន្ត្រីបច្ចេកទេសមធ្យមដើមខ្សែពិសេស	៦
		២. មន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ	៤
		៣. មន្ត្រីបច្ចេកទេសមធ្យម	៤
	គ	មន្ត្រីបច្ចេកទេសបឋម	១០
អង្គគ្រូបង្រៀន[12]	ក	១. គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស	៦
		២. គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ	៤
		៣. គ្រូបង្រៀនកម្រិតឧត្តម	៤
	ខ	១. គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែពិសេស	៦
		២. គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ	៤
		៣. គ្រូបង្រៀនកម្រិតមូលដ្ឋាន	៤
	គ	គ្រូបង្រៀនកម្រិតបឋម	១០
អង្គសុខាភិបាល[13]	ក	១. មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស	៦

[10] ស្ថិតក្រោមឱវាទក្រសួងមហាផ្ទៃ។ *សូមមើល* ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤, ២២ កុម្ភៈ ២០០០ (ក្របខណ្ឌ ក), ព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥, ២២ មេសា ២០០០ (ក្របខណ្ឌ ខ), ព្រះរាជក្រឹត្យលេខ នស/រកត/០៥០០/០៩៦, ១៩ ឧសភា ២០០០ (ក្របខណ្ឌ គ)

[11] ស្ថិតក្រោមការគ្រប់គ្រងផ្ដាល់របស់ក្រសួង/ស្ថាប័ននីមួយៗ និងក្រោមការគ្រប់គ្រងរួមរបស់ក្រសួងមុខងារសាធារណៈ។ *សូមមើល* ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១, ០៩ មិថុនា ២០០២ (ក្របខណ្ឌ ក), ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥២, ០៩ មិថុនា ២០០២ (ក្របខណ្ឌ ខ), ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៣, ០៩ មិថុនា ២០០២ (ក្របខណ្ឌ គ)

[12] ស្ថិតក្រោមឱវាទនៃក្រសួងអប់រំ យុវជន និងកីឡា។ *សូមមើល* ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០, ២៣ កក្កដា ២០០១ (ក្របខណ្ឌ ក), ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤១, ២៣ កក្កដា ២០០១ (ក្របខណ្ឌ ខ), ព្រះរាជក្រឹត្យលេខ នស/រកត/០៩០១/៣៤១, ២៩ កញ្ញា ២០០១ (ក្របខណ្ឌ គ)

[13] ស្ថិតក្រោមឱវាទនៃក្រសួងសុខាភិបាល។ *សូមមើល* ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣, ២១ មិថុនា ២០០២ (ក្របខណ្ឌ ក), ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៤, ២១ មិថុនា ២០០២ (ក្របខណ្ឌ ខ), ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៥, ២១ មិថុនា ២០០២ (ក្របខណ្ឌ គ)

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាគ្រាជ្ញ
ខែទិច្ឆិកា ឆ្នាំ២០១៨

		២. មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ	៤
		៣. មន្ត្រីសុខាភិបាលជាន់ខ្ពស់	៤
	ខ	១. មន្ត្រីសុខាភិបាលមធ្យមដើមខ្សែពិសេស	៦
		២. មន្ត្រីសុខាភិបាលមធ្យមដើមខ្សែ	៤
		៣. មន្ត្រីសុខាភិបាលមធ្យម	៤
	គ	មន្ត្រីសុខាភិបាលបឋម	១០
អង្គការទូត[14]	ក	១. ឧត្តមមន្ត្រីការបរទេស	៦
		២. វរមន្ត្រីការបរទេស	៤
		៣. អនុមន្ត្រីការបរទេស	៤
	ខ	១. នាយក្រមការការបរទេស	៦
		២. ក្រមការដើមខ្សែការបរទេស	៤
		៣. ក្រមការការបរទេស	៤
អង្គមន្ត្រីជាន់ខ្ពស់សវនកម្ម នៃអាជ្ញាធរសវនកម្មជាតិ[15]	ក	១. សវនករដើមខ្សែពិសេស	៦
		២. សវនករដើមខ្សែ	៤
		៣. សវនករ	៤
អង្គមន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត[16]	ក	១. ឧត្តមមន្ត្រី	៦
		២. វរមន្ត្រី	៤
		៣. អនុមន្ត្រី	៤
	ខ	១. នាយក្រមការ	៦
		២. ក្រមការដើមខ្សែ	៤
		៣. ក្រមការ	៤
	គ	ក្របខណ្ឌមន្ត្រីបោះឆ្នោតបឋម	១០

នៅមានលក្ខន្តិក:ដោយឡែកពិសេសមួយចំនួនទៀត ដែលបង្កើតដោយព្រះរាជក្រឹត្យ ដូចជា ក្របខណ្ឌមន្ត្រីនគរបាលជាតិ មន្ត្រី និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែត ។ល។ លើកលែងតែក្របខណ្ឌមន្ត្រីធនាគារជាតិនៃកម្ពុជា ដែលត្រូវបង្កើតដោយប្រកាសរបស់ទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា។

[14] ស្ថិតក្រោមឱវាទនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ *សូមមើល* ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥, ២៦ មេសា ២០០១ (ក្របខណ្ឌ ក), ព្រះរាជក្រឹត្យលេខ នស/រកត/០១០២/០០១, ០៣ មករា ២០០២ (ក្របខណ្ឌ ខ)

[15] ស្ថិតក្រោមឱវាទនៃអាជ្ញាធរសវនកម្មជាតិ។ *សូមមើល* ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៣៩, ១៩ សីហា ២០០៩

[16] ស្ថិតក្រោមឱវាទនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ *សូមមើល* ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៥/៦៤៨, ១៧ មិថុនា ២០១៥

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជ្ញ
ខែទិច្ឆិកា ឆ្នាំ២០១៨

ខ. លក្ខខណ្ឌក្នុងការចូលក្របខណ្ឌ

ការចូលក្របខណ្ឌមុខងារសាធារណៈ ត្រូវធ្វើតាមរយៈការប្រលងប្រជែងជាសាធារណៈ លើកលែងតែមានការកំណត់ផ្សេងដោយរាជរដ្ឋាភិបាល។ ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលអាចតែងតាំងឱ្យចូល ក្របខណ្ឌអ្នករាជការនៅពេលណាក៏បាន ចំពោះវរជន ឬជនដែលមានសញ្ញាបត្រខ្ពស់ ហើយមានផលប្រយោជន៍សម្រាប់ការងាររដ្ឋ ដោយមិនគិតលក្ខខណ្ឌអាយុទេ។ ជាទូទៅ លក្ខខណ្ឌក្នុងការចូលក្របខណ្ឌមុខងារសាធារណៈ គឺ ÷[17]

- មានសញ្ជាតិខ្មែរ (ត្រូវមានសំបុត្រអាត្រានុកូលដ្ឋាន ឬសាលក្រមជំនួសអាត្រានុកូលដ្ឋាន[18])
- ត្រូវមានអាយុយ៉ាងតិច ១៨ឆ្នាំ និងមិនលើស ២៥ឆ្នាំ (ត្រូវកំណត់តាមសំបុត្រអាត្រានុកូលដ្ឋាន ឬសាលក្រមជំនួសអាត្រានុកូលដ្ឋាន) តែអាចមានលក្ខខណ្ឌលើកលែង[19] ដូចខាងក្រោម÷
  - → បេក្ខជនមានសញ្ញាបត្របណ្ឌិត ត្រូវលើកលែងលក្ខខណ្ឌអាយុ
  - → បេក្ខជនមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬសមមូល ត្រូវមានអាយុច្រើនបំផុត ៤០ឆ្នាំ
  - → បេក្ខជនមានសញ្ញាបត្របរិញ្ញាបត្រ ឬសមមូល ត្រូវមានអាយុយ៉ាងច្រើនបំផុត ៣៥ឆ្នាំ
  - → បេក្ខជនជាមន្ត្រីរាជការ ហើយចូលរួមប្រលងប្រជែងក្នុងក្របខណ្ឌផ្សេង ត្រូវលើកលែងលក្ខខណ្ឌអាយុ
- មិនប្រាសចាកសិទ្ធិរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមិនធ្លាប់ជាប់ទោសមជ្ឈឹម ឬព្រហ្មទណ្ឌប៉ះពាល់ដល់ទំនៀមទំលាប់ ប្រពៃណី (ត្រូវមានលិខិតថ្កោលទោសចេញដោយក្រសួងយុត្តិធម៌)
- មានកាយសម្បទាគ្រប់គ្រាន់ក្នុងការបំពេញការងារ ដែលលក្ខណៈសម្បត្តិមានចែងទុកជាមុនក្នុងសេចក្តីណែនាំ ឬបទបញ្ជាជាធរមាន
- បងប្អូនជនជាតិភាគតិច បងប្អូននៅតំបន់ដាច់ស្រយាល នារីភេទ អាចត្រូវផ្តល់អាទិភាព
- លក្ខខណ្ឌពិសេស ដែលចែងក្នុងអង្គដោយឡែក ដែលខ្លួនចង់ចូលបំពេញការងារ។

ពេលប្រលងជាប់ជាមន្ត្រីរាជការ បេក្ខជនជាសិស្សនិស្សិតត្រូវឆ្លងកាត់កម្មសិក្សារយៈពេល ១២ខែ រីឯមន្ត្រីរាជការដែលប្រលងចូលក្របខណ្ឌផ្សេង ត្រូវឆ្លងកាត់រយៈពេលកម្មសិក្សា ៦ខែ។ ក្រោយបញ្ចប់កម្មសិក្សាជោគជ័យ កម្មសិក្សាការីត្រូវតាំងស៊ប់ជាអ្នករាជការ ទៅតាមប្រភេទក្របខណ្ឌដែលខ្លួនប្រលងចូលគឺ ក្របខណ្ឌ ក ដោយព្រះរាជក្រឹត្យ ក្របខណ្ឌ ខ ដោយអនុក្រឹត្យ និងក្របខណ្ឌ គ ដោយប្រកាសរបស់ក្រសួងមុខងារសាធារណៈ។

សូមបញ្ជាក់ផងដែរថា ការប្រលងប្រជែងជាសាធារណៈនេះ អាចធ្វើឡើងតាមរយៈវិធីសាស្ត្រ ២ គឺ÷

---

[17] ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលឆ្នាំ១៩៩៤, មាត្រា១១

[18] សាលក្រមជំនួសអាត្រានុកូលដ្ឋាន សំដៅលើ សេចក្តីសម្រេចរបស់តុលាការរាជធានី-ខេត្ត ដែលពាក់ព័ន្ធនឹងកិច្ចការអាត្រានុកូលដ្ឋាន ដូចមានចែងក្នុង **ច្បាប់ស្តីពីសញ្ជាតិ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨, អនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពី **អាត្រានុកូលដ្ឋាន** និងអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី **ការកែសម្រួលមាត្រា៩ និងមាត្រា៥២** នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពី អាត្រានុកូលដ្ឋាន

[19] អនុក្រឹត្យស្តីពី ការលើកលែងលក្ខខណ្ឌអាយុនិងការកំណត់អាយុបេក្ខជនចូលរួមប្រលងប្រជែងជ្រើសរើសចូលក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល, លេខ៥៩ អនក្រ.បក, ២៤ មករា ២០១៧, មាត្រា៤ និង៥

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជ្ញ
ខែទិច្ឆិកា ឆ្នាំ២០១៨

១. ក្រសួង/ស្ថាប័នរៀបចំផែនការប្រចាំឆ្នាំទាក់ទងនឹងការគ្រប់គ្រងធនធានមនុស្សក្នុងស្ថាប័នរបស់ខ្លួន និងលើកសំណើមកកាន់ក្រសួងមុខងារសាធារណៈ ដើម្បីពិនិត្យ និងសម្រេចលើចំនួនមន្ត្រី និងលើកសំណើក្នុងផែនការចរិការបស់ខ្លួនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យលទ្ធភាពចរិកក្នុងគម្រោងប្រចាំឆ្នាំ។ ក្រោយទទួលបានការអនុម័តចំនួនមន្ត្រីថ្មីរួចរាល់ ក្រសួងសាមីអាចប្រកាសជ្រើសរើស និងរៀបចំការប្រលងដោយខ្លួនឯងក៏បាន ឬផ្ទុកផ្តាក់ការរៀបចំនេះលើក្រសួងមុខងារសាធារណៈក៏បាន។ សម្រាប់ មន្ត្រីថ្មី ដែលប្រលងជាប់តាមក្រសួងស្ថាប័ន ÷

- ក្របខណ្ឌ ក÷ ទទួលបានឋានន្តរសក្តិទី៣ ថ្នាក់ទី៤ (ក.៣.៤)។ ឧទាហរណ៍ ក្នុងអង្គមន្ត្រីគ្រប់គ្រងរដ្ឋបាលត្រូវហៅថា **អនុមន្ត្រី ថ្នាក់ទី៤**
- ក្របខណ្ឌ ខ÷ ទទួលបានឋានន្តរសក្តិទី៣ ថ្នាក់ទី៤ (ខ.៣.៤)។ ឧទាហរណ៍ ក្នុងអង្គរដ្ឋបាលស៊ីវិលក្រសួងមហាផ្ទៃ ត្រូវហៅថា **មន្ត្រីក្រមការក្រសួងមហាផ្ទៃ ថ្នាក់ទី៤**
- ក្របខណ្ឌ គ ÷ គ្មានឋានន្តរសក្តិទេ ដោយទទួលបានថ្នាក់ទី១០ (គ.១០)។ ឧទាហរណ៍ ក្នុងអង្គគ្រូបង្រៀនត្រូវហៅថា **គ្រូបង្រៀនកម្រិតបឋម ថ្នាក់ទី១០**

២. ការប្រលងប្រជែងចូលជាមន្ត្រីរាជការតាមរយៈ**សាលាភូមិន្ទរដ្ឋបាល** ដែលក្រោយពេលប្រលងជាប់ ត្រូវទទួលការបណ្តុះបណ្តាលជំបូងសិន[20] ទើបបញ្ជូនទៅបម្រើការងារនៅតាមក្រសួង/ស្ថាប័ន។ កម្មវិធីបណ្តុះបណ្តាលជំបូងមាន ២ គឺ[21] ÷

- **សិស្សមន្ត្រីជាន់ខ្ពស់** ÷ លក្ខខណ្ឌនៃការប្រលងគឺ លក្ខខណ្ឌនៃក្របខណ្ឌ ក។ ក្រោយប្រលងជាប់ក្លាយជាសិស្សមន្ត្រីជាន់ខ្ពស់ បេក្ខជនត្រូវឆ្លងកាត់ការសិក្សារយៈពេល ២៤ខែ។ សិស្សមន្ត្រីជាន់ខ្ពស់ដែលបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវឆ្លងកាត់រយៈពេលកម្មសិក្សា ១២ខែ ដូចមន្ត្រីដែលប្រលងប្រជែងតាមក្រសួងស្ថាប័នដែរ។ នៅពេលបញ្ចប់ការសិក្សា សិស្សមន្ត្រីជាន់ខ្ពស់នឹងទទួលបានឋានន្តរសក្តិទី៤ ថ្នាក់ទី១ (ក.៣.១) នៃអង្គរបស់ខ្លួន និងទទួលបានប្រាក់បំណាច់មុខងារស្មើនឹងមុខងារជាអនុប្រធាននាយកដ្ឋាន រហូតដល់ពេលបុគ្គលនោះ បានទទួលការតែងតាំងក្នុងមុខតំណែង ដែលមានប្រាក់បំណាចមុខងារលើសពីនេះ[22]។
- **សិស្សមន្ត្រីក្រមការ**÷ លក្ខខណ្ឌនៃការប្រលងគឺ លក្ខខណ្ឌនៃក្របខណ្ឌ ខ។ ក្រោយប្រលងជាប់ក្លាយជាសិស្សមន្ត្រីក្រមការ បេក្ខជនត្រូវឆ្លងកាត់ការសិក្សារយៈពេល ១២ខែ។ សិស្សមន្ត្រីក្រមការដែលបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវឆ្លងកាត់រយៈពេលកម្មសិក្សា ១២ខែ ដូចមន្ត្រីដែលប្រលងប្រជែងតាមក្រសួង/ស្ថាប័នដែរ។ នៅពេលបញ្ចប់ការសិក្សា សិស្សមន្ត្រីក្រមការដែលមានកម្រិតសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបូក ២ឆ្នាំ នឹងទទួលបានឋានន្តរសក្តិទី៤ ថ្នាក់ទី២ (ខ.៣.២) រីឯសិស្សមន្ត្រីក្រមការដែលមានកម្រិតសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបូក៤ឆ្នាំ នឹងទទួលបានឋានន្តរសក្តិទី៤ ថ្នាក់ទី១ (ខ.៣.១) នៃអង្គរបស់ខ្លួន ហើយ

[20] អនុក្រឹត្យស្តីពីលក្ខន្តិក:របស់សាលាភូមិន្ទរដ្ឋបាល, លេខ១៩៧អនក្រ.បក, ០៤ មិថុនា ២០១៤, មាត្រា៦ និងមាត្រា២២

[21] ព្រះរាជក្រឹត្យស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខនស/រកត/០៤៩៥/៤០ចុះថ្ងៃទី២១ខែមេសាឆ្នាំ១៩៩៥ស្តីពី ការបង្កើតសាលាភូមិន្ទរដ្ឋបាល, លេខនស/រកត/០២១៤/១៩៥, ១៧ កុម្ភៈ ២០១៤

[22] អនុក្រឹត្យស្តីពីការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល, លេខ៣៦ អនក្រ.បក, ១៨ មីនា ២០១៥,មាត្រា៩

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាគ្រាជ្ញ
ខែទិច្ឆិកា ឆ្នាំ២០១៨

ទទួលបានប្រាក់បំណាច់មុខងារស្មើនឹងមុខតំណែងជាអនុប្រធានការិយាល័យថ្នាក់កណ្តាល រហូតដល់ពេលបុគ្គលនោះ បានទទួលការតែងតាំងក្នុងមុខតំណែង ដែលមានប្រាក់បំណាចមុខងារលើសពីនេះ។

គ. កម្រៃជីវភាពប្រចាំខែរបស់មន្ត្រីរាជការ

យោងតាមច្បាប់ស្តីពីវិសោធនកម្មច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលឆ្នាំ២០១៣ និងព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីប្រាក់បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស កម្រៃជីវភាពប្រចាំខែរបស់មន្ត្រីរាជការក្រោម ត្រូវបែងចែកជា ប្រាក់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់ហានិភ័យ និងប្រាក់វិភាជន៍គ្រួសារ[23]។

ប្រាក់បៀវត្សមូលដ្ឋាន ត្រូវគណនាដោយយក **សន្ទស្សន៍ប្រាក់បៀវត្សមូលដ្ឋាន** កំណត់ក្នុងព្រះរាជក្រឹត្យស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈឆ្នាំ២០១៤ គុណនឹង **តម្លៃឯកតានៃសន្ទស្ស** ដែលកំណត់ និងអាចកែប្រែបានដោយអនុក្រឹត្យ។ គិតពីថ្ងៃ០១ ខែមករា ឆ្នាំ២០១៩ តម្លៃមួយឯកតានៃសន្ទស្សន៍ប្រាក់បៀវត្សគឺ ២៣៤០ រៀល[24]។

ប្រភេទក្របខណ្ឌ	ឋានន្តរស័ក្តិ												
ក	៣				២				១				
	ថ្នាក់				ថ្នាក់				ថ្នាក់				
	៤	៣	២	១	៤	៣	២	១	៦	៥	៤	៣	២	១
	សន្ទស្សន៍បៀវត្ស				សន្ទស្សន៍បៀវត្ស				សន្ទស្សន៍បៀវត្ស					
	៣៨៥	៣៩៨	៣៦៨	៣៣៩	៣៩៨	៤១០	៤២៦	៤៨៣	៤៦១	៤៣៩	៤៩៦	៥១៣	៥៣១	៥៥០
ប្រភេទក្របខណ្ឌ	ឋានន្តរស័ក្តិ												
ខ	៣				២				១				
	ថ្នាក់				ថ្នាក់				ថ្នាក់				
	៤	៣	២	១	៤	៣	២	១	៦	៥	៤	៣	២	១
	សន្ទស្សន៍បៀវត្ស				សន្ទស្សន៍បៀវត្ស				សន្ទស្សន៍បៀវត្ស					
	៣០០	៣០៨	៣១៨	៣៣១	៣៤៤	៣៥៨	៣៦៩	៣៨០	៣៩៣	៤០៣	៤២១	៤៣៦	៤៥៣	៤៧០
ប្រភេទក្របខណ្ឌ	ថ្នាក់												
គ	១០	៩	៨	៧	៦	៥	៤	៣	២	១			
	សន្ទស្សន៍បៀវត្ស												
	២៦៥	២៧៨	២៨៤	២៩៥	៣០៧	៣២១	៣៣៥	៣៥២	៣៧០	៣៩០			

តារាងសន្ទស្សន៍ប្រាក់បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល

(ប្រភព÷ ព្រះរាជក្រឹត្យស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋឆ្នាំ២០១៤)

---

[23] យោងតាមមាត្រា១០ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការឆ្នាំ១៩៩៤ របបប្រាក់កម្រៃជីវភាពមន្ត្រីរាជការត្រូវកំណត់ដោយច្បាប់ដោយឡែក។ ប៉ុន្តែក្នុងស្ថានភាពចាំបាច់នាពេលនោះ រាជរដ្ឋាភិបាលសម្រេចស្នើទៅ ព្រះមហាក្សត្រ សូមព្រះបរមរាជានុញ្ញាតឲ្យព្រះហស្តលេខាលើ ព្រះរាជក្រឹត្យស្តីពីប្រាក់បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ក្នុងឆ្នាំ២០០១។ ក្រោយមក តាមរយៈមាត្រា ១០ថ្មី នៃ ច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា *"របបបៀវត្ស និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ។ ការកែសម្រួលរបបបៀវត្ស និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ត្រូវកំណត់ដោយអនុក្រឹត្យ"*

[24] អនុក្រឹត្យស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា, លេខ១៧៣ អនក្រ.បក, ១៨ ធ្នូ ២០១៨ តំណភ្ជាប់ https://goo.gl/SgK7yX

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជ្ញ
ខែទិច្ឆិកា ឆ្នាំ២០១៨

ប្រាក់បំណាច់មុខងារ សំដៅលើប្រាក់បន្ថែមលើបៀវត្សមូលដ្ឋានប្រចាំខែរបស់មន្ត្រីរាជការស៊ីវិល ដែលកំពុងបំពេញមុខងារក្នុងមុខតំណែងតាមរចនាសម្ព័ន្ធរបស់ក្រសួង/ស្ថាប័ន[25]។ ប្រាក់បំណាច់មុខងារ អាចកែប្រែបានដោយអនុក្រឹត្យ ក្នុងគោលដៅបង្កើនជីវភាពមន្ត្រីរាជការ ដោយចុងក្រោយ ត្រូវបានធ្វើឡើងតាមរយៈ អនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ ស្តីពីការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល[26]។

វិធីសាស្ត្រក្នុងការគណនាប្រាក់បៀវត្សគឺ **(តម្លៃឯកតា x សន្ទស្សន៍បៀវត្ស) + ប្រាក់បំណាច់មុខងារ**។ ឧទាហរណ៍ មន្ត្រីថ្មី (ក្របខណ្ឌ ក) មានស្ថានភាពគ្រួសារនៅលីវ ត្រូវទទួលប្រាក់បំណាច់មុខងារជាមន្ត្រីគ្រប់គ្រងរដ្ឋបាល គឺ (២.៣៤០៛ x ៣៤៥) + ៤៧០.០០០៛ = ១.២៧៣.៣០០៛[27] ។

ប្រាក់វិភាជន៍គ្រួសារ ត្រូវបានកំណត់សម្រាប់ភរិយា/ស្វាមី ត្រូវផ្តល់ ៦.០០០៛ ទៅ ១៥.០០០៛ ផ្អែកតាមសំបុត្រអាពាហ៍ពិពាហ៍ និងសម្រាប់កូន ត្រូវផ្តល់ពី ៥.០០០៛ ទៅ ១០.០០០៛ ផ្អែកតាមសំបុត្រកំណើត[28]។

ប្រាក់ហានិភ័យ គឺជាប្រាក់ប្រចាំខែសម្រាប់ផ្តល់ជូនមន្ត្រីរាជការណាដែលត្រូវបានចាត់ទៅបំពេញការងារនៅទីកន្លែងដែលមានគ្រោះថ្នាក់ ជំងឺឆ្លង ការងារប៉ះពាល់សុខភាព ឬខូចសុខភាព។ ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ស្តីពីប្រាក់បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ប្រាក់ហានិភ័យ បែងចែកជា ២ គឺ ប្រាក់ប៉ះពាល់សុខភាព និងប្រាក់តំបន់។ សព្វថ្ងៃ រាជរដ្ឋាភិបាលបានកំណត់ប្រាក់តំបន់សម្រាប់មន្ត្រីរាជការក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ដោយមានបែងចែកជា ៣កម្រិត គឺ តំបន់ជួបការលំបាក ទទួលបាន ៨០.០០០៛ តំបន់ដាច់ស្រយាលប្រភេទ១ ទទួលបាន ១០០.០០០៛ និង តំបន់ដាច់ស្រយាលប្រភេទ២ ទទួលបាន ១២០.០០០៛[29]។

ចំពោះ **ផ្នែកហានិភ័យការងារ** វិញ រាជរដ្ឋាភិបាលកំពុងរៀបចំរបបសន្តិសុខសង្គម តាមរយៈ ព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧[30]។ តាមរយៈអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ រាជរដ្ឋាភិបាលក៏បានកំណត់លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន តែមិនរាប់បញ្ចូលអតីតយោធិន ដែលមានឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ និងឧត្តមនាវី។

---

[25] អនុក្រឹត្យស្តីពីការកែសម្រួលប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល, លេខ៣៦ អនក្រ.បក, ១៨ មីនា ២០០៥, មាត្រា៤, សូមមើលបន្ថែមតាមតំណភ្ជាប់ https://goo.gl/qT9Hnh

[26] សូមមើលបន្ថែមតាមរយៈតំណភ្ជាប់ https://goo.gl/FQ5ZYk

[27] ប្រាក់បៀវត្ស ពុំទាន់រាប់បញ្ចូលប្រាក់រង្វាន់ និងប្រាក់ឧបត្ថម្ភផ្សេងៗនៅឡើយទេ ហើយត្រូវជាកម្មវត្ថុនៃការកាត់ពន្ធលើប្រាក់បៀវត្ស តាមបទប្បញ្ញត្តិនៃច្បាប់សារពើពន្ធ ដែលមានជាធរមាន

[28] អនុក្រឹត្យស្តីពីការដំឡើងប្រាក់វិភាជន៍គ្រួសាររបស់មន្ត្រីរាជការស៊ីវិល ប្រាក់បំណាច់ឧបត្ថម្ភគ្រួសារនិងកូនយោធិននៃកងយោធពលខេមរភូមិន្ទ, មន្ត្រីនគរបាលជាតិកម្ពុជា មន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ, លេខ២៧៨ អនក្រ.បក, ២៩ ធ្នូ ២០១៦

[29] អនុក្រឹត្យស្តីពីប្រាក់តំបន់សម្រាប់មន្ត្រីរាជការស៊ីវិលក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល, លេខ៣៧ អនក្រ.បក, ១៨ មីនា ២០១៥

[30] សូមមើលបន្ថែមតាមរយៈតំណភ្ជាប់ https://goo.gl/qdPGWP

©អក្សរសិទ្ធិគ្រប់យ៉ាងដោយសាលាគ្រាជ្ញ
ខែទីជ្ជិកា ឆ្នាំ២០១៨

គួរបញ្ជាក់ផងដែរថា សព្វថ្ងៃនេះ ក្រសួងស្ថាប័នមួយចំនួន ដែលទទួលបន្ទុកបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ និងប្រមូលចំណូលសេវាសាធារណៈចូលថវិកាជាតិ ត្រូវបានអនុញ្ញាតឱ្យកាត់ភាគរយពីចំណូលសរុប សម្រាប់បែងចែកជូនមន្ត្រីរាជការក្នុងក្រសួងសាមីជារង្វាន់លើកទឹកចិត្ត។ ចំនួនភាគរយជាក់ស្តែង ត្រូវកំណត់ដោយប្រកាសរួមរបស់ប្រធានស្ថាប័នសាមី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ឧទាហរណ៍ ប្រកាសអន្តរក្រសួងលេខ១១៨៧០ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៥ រវាង **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និង**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ស្តីពី ការគ្រប់គ្រងប្រាក់ចំណូល ដែលបានមកពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសច្បាប់ស្តីពីចរាចរណ៍។

ឃ. របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ

មន្ត្រីរាជការស៊ីវិល ត្រូវដាក់ឱ្យចូលនិវត្តន៍ជាកំហិតត្រឹមអាយុ៥៥ឆ្នាំ។ លក្ខខណ្ឌអាយុអាចរំកិលដល់ ៦០ឆ្នាំ បើលក្ខន្តិកៈដោយឡែកនៃមន្ត្រីនោះកំណត់ផ្សេង។

ចំពោះ **របបសោធននិវត្តន៍** គឺត្រូវកំណត់ចំពោះមន្ត្រីរាជការ ដែលបំពេញគ្រប់លក្ខខណ្ឌ ៣ ខាងក្រោម÷[31]

- អ្នករាជការដែលបំពេញការងារបាន៣០ឆ្នាំយ៉ាងតិចទទួលបាន **ប្រាក់សោធនអតីតភាព** ស្មើនឹង៨0% នៃប្រាក់បៀវត្សមូលដ្ឋានខែចុងក្រោយ
- អ្នករាជការដែលបំពេញការងារក្នុងចន្លោះរយៈពេល ២០ឆ្នាំទៅក្រោម ៣០ឆ្នាំ ត្រូវទទួលបាន **ប្រាក់សោធនសមាមាត្រ**
- សម្រាប់អ្នកដែលមានអតីតភាពការងារតិចជាង ២០ឆ្នាំ ត្រូវទទួលប្រាក់សោធននិវត្តន៍ ដែលបានកាត់ទុក និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់រដ្ឋតែម្តងគត់
- រីឯអ្នករាជការណា ដែលក្រសួងស្ថាប័នប្រកាសឱ្យចូលនិវត្តន៍ ត្រូវទទួលបានប្រាក់ឧបត្ថម្ភម្តងគត់ស្មើនឹងបៀវត្សសុរបប្រចាំខែចំនួន ៨ខែ។

ចំពោះ **របបសោធនបាត់បង់សម្បទាវិជ្ជាជីវៈ** ត្រូវផ្តល់ទៅឱ្យអ្នករាជការណាដែលបាត់បង់សមត្ថភាព និងសម្បទាវិជ្ជាជីវៈក្នុងការបំពេញការងារ និងលក្ខខណ្ឌដូចខាងក្រោម÷[32]

- មន្ត្រីរាជការបាត់បង់សម្បទាវិជ្ជាជីវៈ ហើយមានអតីតភាពការងារ៣០ឆ្នាំយ៉ាងតិច ត្រូវទទួលបានសោធនអតីតភាព
- ក្នុងករណីមិនបានបំពេញគ្រប់លក្ខខណ្ឌទទួលប្រាក់សោធនអតីតភាព មន្ត្រីនោះអាចត្រូវបញ្ឈប់ពេលណាក៏បាន។ ប្រសិនបើមន្ត្រីរាជការបាត់បង់សម្បទាវិជ្ជាជីវៈ មានអតីតភាពការងារលើសពី២០ឆ្នាំ មានសិទ្ធិទទួលប្រាក់សោធនសមាមាត្រ។ បើអតីតភាពក្រោម២០ឆ្នាំ មានសិទ្ធិទទួលបានប្រាក់សោធនដែលបានកាត់ទុក និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់រដ្ឋតែមួយលើក។

[31] ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលឆ្នាំ១៩៩៤, មាត្រា៥៤ និង៥៥
[32] ដដែល, មាត្រា១៩

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជ្ញ
ខែទិន្នីកា ឆ្នាំ២០១៨

- ការកំណត់ថាបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវសម្រេចដោយគណៈកម្មការមួយ ដឹកនាំដោយប្រធានស្ថាប័នរបស់សាមីជននោះ។

វិធីសាស្ត្រក្នុងការគណនា របបសោធននិវត្តន៍ និងរបបសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវបានកំណត់លម្អិតបន្ថែមក្នុង **អនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ** របស់រាជរដ្ឋាភិបាល ហើយដែលបានអនុវត្តមកទល់សព្វថ្ងៃ[33]។

ឯ. សិទ្ធិ និងកាតព្វកិច្ចរបស់មន្ត្រីរាជការ

ក្រៅពីសិទ្ធិទទួលបានប្រាក់បៀវត្ស និងសិទ្ធិលើប្រាក់សោធននិវត្តន៍និងសោធនបាត់បង់វិជ្ជាជីវៈ មន្ត្រីរាជការស៊ីវិលទទួលបានសិទ្ធិមួយចំនួនទៀតដូចជា សិទ្ធិសុំផ្លាស់កន្លែងធ្វើការទៅតាមសហព័ទ្ធ[34] សិទ្ធិក្នុងការឡើងថ្នាក់និងឋានន្តរសក្តិ សិទ្ធិចូលជាសមាជិក ឬចូលរួមក្នុងការគ្រប់គ្រងសមាគមស្របច្បាប់[35] និងសិទ្ធិក្នុងប្តឹងតវ៉ាទៅតុលាការពាក់ព័ន្ធនឹងមុខងារសាធារណៈ។ ចំពោះការឡើងឋានន្តរសក្តិ ឬថ្នាក់ គឺអាចតាមវេនជ្រើសរើស ឬតាមវេនជ្រើសរើសនិងអតីតភាពជាមួយគ្នា។ អប្បបរមានៃការឡើងថ្នាក់គឺ ២ឆ្នាំម្តង និងត្រូវធ្វើឡើងតាមរយៈព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស។ ប៉ុន្តែសិទ្ធិនេះនឹងត្រូវផ្អាក ប្រសិនបើមន្ត្រីនោះទទួលទណ្ឌកម្មវិន័យ ឬការចោទប្រកាន់តាមផ្លូវតុលាការ។ ក្នុងពេលមានការចោទប្រកាន់រឿងវិន័យ ឬផ្លាស់ដោយបង្ខំ មន្ត្រីរាជការមានសិទ្ធិសុំមើលសំណុំរឿងរបស់ខ្លួន សិទ្ធិសំអាងសាក្សី សិទ្ធិជ្រើសរើសតំណាងការពារ និងសិទ្ធិក្នុងការពន្យល់ដោះសារជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់។[36]

ជាកាតព្វកិច្ច មន្ត្រីរាជការត្រូវតែគោរពច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងបទបញ្ជារបស់ថ្នាក់លើខ្លួន ព្រមទាំងការចាត់បញ្ជូនឱ្យទៅធ្វើការទាំងក្នុង និងក្រៅប្រទេស។ មន្ត្រីរាជការក៏ត្រូវទទួលខុសត្រូវចំពោះរាល់កិច្ចការងាររបស់ខ្លួនចំពោះថ្នាក់លើ និងអំពើណាមួយដែលធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ខ្លួន និងរបស់អង្គភាព។ មន្ត្រីរាជការមិនអាចឈប់សម្រាកដោយគ្មានការអនុញ្ញាតពីអង្គភាពរបស់ខ្លួនឡើយ ហើយរបបនៃការឈប់សំរាក ត្រូវកំណត់ដោយ **អនុក្រឹត្យលេខ២១៧ អនក្រ.បក ស្តីពី របបស្តីពីការសុំច្បាប់និងការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទរបស់មន្ត្រីរាជការស៊ីវិលនៃ ព្រះរាជាណាចក្រកម្ពុជា**[37]។ មន្ត្រីរាជការស៊ីវិល ត្រូវអព្យាក្រឹត្យពីសកម្មភាពនយោបាយ និងជាពិសេសត្រូវបង្ហាញថា ខ្លួនមានសមត្ថភាពក្នុងការបំពេញវិជ្ជាជីវៈរបស់ខ្លួនជាដរាប ព្រមទាំងត្រូវហ៊ានទទួលខុសត្រូវចំពោះកំហុស និងការឆ្គាំឆ្គងវិជ្ជាជីវៈនានា ព្រមទាំងបទល្មើសដែលខ្លួនប្រព្រឹត្ត។ មន្ត្រីរាជការ ត្រូវហាមឃាត់ដាច់ខាតមិនឱ្យប្រព្រឹត្តអំពើដូចខាងក្រោម÷[38]

- យកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្ទាល់ខ្លួនផ្សេងៗទៀត

[33] សូមមើលបន្ថែមតាមរយៈតំណភ្ជាប់ https://goo.gl/MU2NNX
[34] ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលឆ្នាំ១៩៩៤, មាត្រា៧
[35] ដដែល, មាត្រា៣៧
[36] ដដែល, ជំពូកទី៤
[37] សូមមើលបន្ថែមតាមរយៈតំណភ្ជាប់ https://goo.gl/xyQGfM
[38] ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលឆ្នាំ១៩៩៤, មាត្រា៦ មាត្រា៣៥ មាត្រា៣៧ មាត្រា៣៨ និងមាត្រា៤៩

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាគ្រាជ្ញ
ខែវិច្ឆិកា ឆ្នាំ២០១៨

- យកឥទ្ធិពល និងអំណាចក្នុងមុខងាររបស់ខ្លួនទៅប្រើ ដើម្បីទាញផលប្រយោជន៍អ្វីមួយ ឬដើម្បីសំឡុតគំរាមកំហែង បំពានសិទ្ធិរបស់ពលរដ្ឋ
- ប្រកបមុខរបរណាដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃអ្នករាជការ
- ចូលជាសមាជិកក្រុមប្រឹក្សាភិបាល ឬគ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ ឬដោយប្រយោល
- បោះពុម្ពផ្សាយ ឬធ្វើការផ្សព្វផ្សាយព័ត៌មាន ដែលមានពាក់ព័ន្ធនៅក្នុងមុខងារក្រសួង ដោយពុំមានការអនុញ្ញាតជាមុនពីប្រធានស្ថាប័ន ដែលសាមីខ្លួននៅក្រោមឱវាទ
- ប្រកបមុខរបរបន្ថែមក្រៅតលើមុខងាររបស់ខ្លួនជាអ្នករាជការ ក្នុងករណីលក្ខន្តិក:ដោយឡែកនៃអង្គនីមួយៗ ហាមឃាត់។

ខុសពីក្របខណ្ឌយោធា ក្របខណ្ឌមន្ត្រីនគរបាលជាតិ និងក្របខណ្ឌចៅក្រម/ព្រះរាជអាជ្ញា សម្រាប់ក្របខណ្ឌមន្ត្រីរាជការស៊ីវិល គេពុំទាន់ឃើញមានក្រមសីលធម៌វិជ្ជាជីវៈក្នុងពេលបំពេញការងាររបស់មន្ត្រីរាជការស៊ីវិល ដែលមានលក្ខណៈលម្អិតនៅឡើយទេ។

ច. វិន័យ ទណ្ឌកម្ម និងការចោទប្រកាន់តាមផ្លូវតុលាការ

វិន័យ ទៅលើមន្ត្រីរាជការស៊ីវិលក្នុងពេលមានកំហុស ត្រូវបានកំណត់ដូចខាងក្រោម÷[39]

- **ទណ្ឌកម្មថ្នាក់ទី១÷** (ក) ការស្តីបន្ទោស (ខ) ការស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន (គ) ការផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ និង (ឃ) ការលុបឈ្មោះចេញពីតារាងឡើងឋានន្តរសក្តិ ឬថ្នាក់។ ការស្តីបន្ទោស ត្រូវធ្វើតាមលិខិតផ្ញើទៅសាមីខ្លួន ដោយប្រធានអង្គភាព ឬប្រធានស្ថាប័ន។ ការស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន ការផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ និងការលុបឈ្មោះចេញពីតារាងឡើងឋានន្តរសក្តិឬថ្នាក់ ត្រូវសម្រេចតាមព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស (ផ្អែកតាមក្របខណ្ឌ ឋានន្តរសក្តិសាមីខ្លួន) តាមសេចក្តីរាយការណ៍ពីប្រធានអង្គភាព និងក្រោយសាមីខ្លួនបានដោះ សារ
- **ទណ្ឌកម្មថ្នាក់ទី២÷** (ក) ស្តីបន្ទោសជាទម្ងន់បណ្តាលឱ្យលុបចេញពីតារាងឡើងឋានន្តរសក្តិ ឬថ្នាក់ បើសិនជាមានចុះឈ្មោះរួចហើយ ឬធ្វើឱ្យយឺតក្នុងការដំឡើងឋានន្តរសក្តិ ឬថ្នាក់ក្នុងចិរវេលាកំណត់ណាមួយ តែមិនត្រូវឱ្យលើស ២ឆ្នាំ ក្នុងការដំឡើងឋានន្តរសក្តិឬថ្នាក់ តាមវេនជ្រើសរើស ឬតាមវេនអតីតភាព (ខ) ដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្សមិនឱ្យលើសពី១ឆ្នាំ (គ) បន្ថយឋានន្តរសក្តិ ឬថ្នាក់ មួយថ្នាក់ ឬច្រើនថ្នាក់ (ឃ) ដាក់ឱ្យចូលនិវត្តន៍មុនកាលកំណត់ ឬបញ្ឈប់ពីការងារដោយបង្ខំ និង (ង) បណ្តេញចេញពីមុខតំណែងរាជការ។ រាល់ទណ្ឌកម្មទាំងអស់នេះ ត្រូវសម្រេចតាមព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស (ផ្អែកតាមក្របខណ្ឌ ឋានន្តរសក្តិសាមីខ្លួន) ក្រោយមានការសម្រេចពីក្រុមប្រឹក្សាវិន័យ។ ការចោទប្រកាន់ខាងផ្នែកវិន័យ ត្រូវធ្វើឡើងដោយគណៈគ្រប់គ្រងដែលមានសមត្ថកិច្ច ក្រោយមានការរាយការណ៍ពីប្រធានអង្គភាព ឬប្រធានស្ថាប័ន។ ក្នុងរយៈពេល១ខែយ៉ាងយូរ ក្រុមប្រឹក្សាវិន័យត្រូវកោះប្រជុំផ្តល់យោបល់។ ចំពោះទណ្ឌកម្មថ្នាក់ទី២ ត្រូវ

[39] ច្បាប់ស្តីពីសហលក្ខន្តិក:មន្ត្រីរាជការស៊ីវិលឆ្នាំ១៩៩៤, មាត្រា៤០ មាត្រា៤១ មាត្រា៤២ មាត្រា៤៥ មាត្រា៤៧ និងមាត្រា៤៨

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាគ្រាជ្ញ
ខែវិច្ឆិកា ឆ្នាំ២០១៨

មានការអង្កេតជាមុនសិន ទើបអាចសម្រេចជាក្រោយ។ ក្រោយអង្កេតរួចរាល់ សំណុំឯកសារត្រូវបញ្ជូនទៅប្រធានស្ថាប័នសាមី ដើម្បីពិនិត្យសម្រេចថា គួរទម្លាក់ការចោទប្រកាន់ ឬបញ្ជូនបន្តទៅក្រុមប្រឹក្សាវិន័យ។ ក្រុមប្រឹក្សាវិន័យមានសមាជិក៥រូបគឺ ៣រូបចាត់តាំងដោយប្រធានស្ថាប័ន ដោយម្នាក់ជាអ្នកធ្វើរបាយការណ៍ ហើយម្នាក់ទៀតជាប្រធាន និង២រូបទៀត នៅក្របខណ្ឌជាមួយនឹងសាមីជាប់ចោទ តែមានឋានន្តរសក្តិខ្ពស់ជាង ឬអតីតភាពការងារចាស់ជាងក្នុងថ្នាក់ជាមួយគ្នា។

ចំពោះមន្ត្រីរាជការស៊ីវិលណាដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយត្រូវព្រះរាជអាជ្ញាសម្រេចចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវជូនដំណឹងអំពីការចោទប្រកាន់ទៅកាន់ប្រធានស្ថាប័នសាមីក្នុងរយៈពេល **៧២**ម៉ោងយ៉ាងយូរ។ បើក្នុងករណីមានការចាប់ខ្លួន ឬឃាត់ខ្លួន ឬឃុំខ្លួនជាបណ្តោះអាសន្ន ព្រះរាជអាជ្ញា ឬចៅក្រមដែលមានសមត្ថកិច្ច ត្រូវរាយការណ៍មកប្រធានស្ថាប័នសាមីជាបន្ទាន់។ ហើយបើក្នុងករណី បទល្មើសនេះកើតឡើងក្នុងក្របខណ្ឌបំពេញមុខងារ រដ្ឋត្រូវតែជួយការពារមន្ត្រីនោះទៅតាមផ្លូវច្បាប់។[40] ក្នុងករណីចាំបាច់ សាមីជននោះអាចត្រូវផ្អាកពីមុខងារជាបណ្តោះអាសន្នសិនក្នុងអំឡុងនីតិវិធីតុលាការ។ ប្រសិនបើសាលក្រមតុលាការប្រកាសថាគ្មានទោសទេ សាមីជននោះនឹងត្រូវទទួលឱ្យចូលធ្វើការវិញភ្លាម ដោយគិតអតីតភាពការងារ ឋានន្តរសក្តិ សោធននិវត្តន៍ និងទទួលបៀវត្ស ដែលផ្អាកក្នុងអំឡុងពេលនីតិវិធីតុលាការមកវិញ។ ប្រសិនបើតុលាការប្រកាសផ្តន្ទាទោសជាបទមជ្ឈឹម ឬបទឧក្រិដ្ឋ សាមីជននោះនឹងបាត់បង់ក្របខណ្ឌមុខងារសាធារណៈរបស់ខ្លួនដោយស្វ័យប្រវត្តិ គិតពីថ្ងៃសាលក្រមចូលជាស្ថាពរ។[41]

ឆ. ការដោះស្រាយទំនាស់មុខងារសាធារណៈ

ដូចបញ្ជាក់ខាងដើម មន្ត្រីរាជការមានសិទ្ធិក្នុងការប្តឹងទៅតុលាការពាក់ព័ន្ធនឹងមុខងារសាធារណៈ ប៉ុន្តែជាការចាំបាច់ ត្រូវប្រកាន់យកការដោះស្រាយតាមវិធីដោះស្រាយជាមុនសិន។ សមត្ថកិច្ចក្នុងការដោះស្រាយត្រូវប្រគល់ទៅឱ្យគណៈកម្មាធិការអចិន្ត្រៃយ៍មួយ ឈ្មោះ **គណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ** ដែលមានរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ជាប្រធាន។[42]

ការសិក្សាអំពីគោលការណ៍ និងខ្លឹមសារគតិយុត្តដូចខាងលើនេះ គឺឆ្លុះបញ្ចាំងពីបទប្បញ្ញត្តិជាធរមាន ដែលមានចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្តតាមឋានានុក្រមចាប់ពី ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីសម្រេចនានារបស់រាជរដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធ និងការធ្វើវិសោធនកម្មឱ្យស្របទៅតាមសភាពការណ៍ប្រទេសជាតិមកទល់សព្វថ្ងៃ។ ការសិក្សានេះបានបង្ហាញឱ្យឃើញពីប្រព័ន្ធគ្រប់គ្រងមួយ ដែលមានរចនាសម្ព័ន្ធច្បាស់លាស់ត្រឹមត្រូវ មានការបែងចែកជាប្រភេទនៃអង្គ ក្របខណ្ឌ ឋានន្តរសក្តិ ថ្នាក់ សន្ទស្សន៍បៀវត្ស ប្រាក់សោធននិវត្តន៍ វិន័យ និងការដោះស្រាយទំនាស់ក្នុងមុខងារសាធារណៈ។

---

[40] ច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៥១នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលឆ្នាំ១៩៩៤, មាត្រា៥១ថ្មី

[41] ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលឆ្នាំ១៩៩៤, មាត្រា៥២ និងមាត្រា៥៣

[42] ដដែល, ជំពូកទី៨

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជ្ញ
ខែទិច្ឆិកា ឆ្នាំ២០១៨

ជាក់ស្តែង នាពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលបានរៀបចំឱ្យមាន ការធ្វើបច្ចុប្បន្នភាពលើប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការសាធារណៈ ដោយបញ្ចូលព័ត៌មានមន្ត្រីសាធារណៈទៅតាមប្រព័ន្ធព័ត៌មានវិទ្យា ការរៀបចំឱ្យមានការបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ និងការព្យាយាមដំឡើងប្រាក់បៀវត្សជារៀងរាល់ឆ្នាំ ដោយរាជរដ្ឋាភិបាលបានកំណត់ឱ្យបានយ៉ាងទាបបំផុត១លានរៀល ក្នុងឆ្នាំ២០១៨ នេះ។

ទោះយ៉ាងណាក្តី ការព្យាយាមខិតខំរបស់រាជរដ្ឋាភិបាលក៏នៅជួបប្រទះនឹងបញ្ហាប្រឈមជាច្រើនផងដែរ ដែលទាមទារឱ្យស្ថាប័នពាក់ព័ន្ធទាំងអស់បង្ហាញឆន្ទៈខ្ពស់ក្នុងការដោះស្រាយ ព្រោះថា បើមានតែលិខិតបទដ្ឋានគតិយុត្ត តែគ្មានឆន្ទៈក្នុងការអនុវត្ត ការកែទម្រង់មិនអាចមានដំណើរការទៅមុខនោះទេ។

****

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាគ្រាជ្ញ
ខែទិន្និកា ឆ្នាំ២០១៨